# ប្រភពនៃទស្សនវិជ្ជាអប់រំ៖ បច្ឆានវនិយម

*ដោយ៖* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

*បច្ឆានវនិយម ឬសម័យក្រោយទំនើបនិយម ដែលជាទស្សនវិជ្ជាទំនើបឈានមុខគេនោះ អះអាងថា សម័យកាលប្រវត្តិសាស្ត្រទំនើបបានបញ្ចប់ទៅហើយ ហើយយើងកំពុងរស់នៅក្នុងសករាជក្រោយសម័យទំនើប។*

*បច្ឆានវនិយម ឬសម័យក្រោយទំនើបនិយម ក្នុងបស្ចិមប្រទេស ជាចលនាទស្សនវិជ្ជាចុងសតវត្សទី២០ ដែលបានកំណត់លក្ខណៈដោយមជ្ឈជាតុនិយម អត្តនោម័តិនិយម ឬសាបេក្ខភាពនិយមយ៉ាងទូលំទូលាយ ការសង្ស័យទូទៅនៃហេតុផល និងភាពរសើបខ្លាំង ចំពោះតួនាទីនៃមនោគមវិជ្ជាក្នុងការអះអាង និងរក្សាអំណាចនយោបាយ និងសេដ្ឋកិច្ច។*

## បច្ឆានវនិយម និងនវទស្សនវិជ្ជា

**បច្ឆានវនិយម** *ភាគច្រើនជាប្រតិកម្មប្រឆាំងនឹងការសន្មតដោយរាងវៃ និងគុណតម្លៃនៃសម័យកាលទំនើប នៅក្នុងប្រវត្តិសាស្ត្រនៃទស្សនវិជ្ជាលោកខាងលិច (ប្រហែលសតវត្សទី១៧ រហូតដល់សតវត្សរ៍ទី១៩)។ ជាការពិត គោលលទ្ធិជាច្រើនដែលមានលក្ខណៈទាក់ទងនឹងក្រោយសម័យទំនើបនិយម អាចត្រូវបានគេពិពណ៌នាដោយត្រឹមត្រូវថាជាការបដិសេធដោយបត្រង់ៗនៃទស្សនៈទស្សនវិជ្ជាទូទៅ ដែលត្រូវបានទទួលយកនៅក្នុងអំឡុងពេលសម័យបច្ចេកវិទ្យានៃសតវត្សរ៍ទី១៨ ទោះបីជាវាមិនមានតែមួយគត់ ចំពោះសម័យនោះ។ ចំណុចសំខាន់បំផុតនៃទស្សនៈទាំងនេះ មានដូចខាងក្រោម៖*

*ដើមកំណើតសម័យក្រោយទំនើបនិយមអាចត្រូវបានរកឃើញក្នុងគំនិតទស្សនវិទូអាល្លឺម៉ង់* Friedrich Nietzsche (1844-1900) and Heidegger (1899-1976)។

Nietzsche *បានទាត់ចោលនូវការប្រ កាសបែបបរមត្ថវិទ្យា អំពីសច្ចភាពដាច់ខាតដោយផ្តល់យោបល់ថា វាត្រូវបានគេប្រឌិដ្ឋឡើង ដើម្បីជំនួសជំនឿធម្មតា និង*

ជំនឿអភិធម្មជាតិ ជាមួយនឹងការអះអាងមិនពិតថ្មីៗ ប៉ុន្តែ មានសមភាព[1]។

ការបង្កើតទស្សនវិជ្ជាមួយ ដែលគេហៅថា ទ្រឹស្តីញាណវិភាគ Heidegger អះអាងថា មនុស្សលោកបង្កើតសច្ចភាពជាអត្តនោម័តិ អំពីតថភាព ពីអព្ភន្តរញាណប្រត្យក្សារម្មណ៍ និងការឆ្លុះបញ្ចាំង នៅពេលដែលគេធ្វើអន្តរកម្មជាមួយបាតុភូត។

ទស្សនវិទូខ្លះ កំណត់គោលលទ្ធិក្រោយសម័យទំនើបនិយមទៅ Nietzsche ខណៈពេលដែលទ្រឹស្តីវប្បធម៌ពណ៌នា អំពីក្រោយសម័យទំនើបថាជាលទ្ធផលនៃការរៀបចំរចនាសម្ព័ន្ធមូលធននិយមនៅចុងសតវត្សរ៍ទី២០។ ខណៈពេលដែលការឆ្លើយតបនៃវប្បធម៌ទំនើបនិយម ចំពោះចរិតលក្ខណៈដ៏វិសេសវិសាលនៃជីវិតសម័យទំនើបប្រកាន់ខ្ជាប់នូវគំនិតនៃសាមគ្គីភាព លទ្ធិក្រោយសម័យទំនើបនិយម ទទួលយកភាពខុសគ្នា និងទំនាស់ ដែលមិនអាចកាត់បន្ថយបានក្នុងកិច្ចការមនុស្ស និងពហុភាពក្នុងរបៀបនៃការយល់ដឹង។ ដោយបានប្រើប្រាស់តាំងពីទសវត្សឆ្នាំ១៩៦០ ដើម្បីនិយាយយោងទៅដល់យុទ្ធសាស្ត្រប្រឆាំងសម័យទំនើបនិយម នៅក្នុងស្ថាបត្យកម្មសិល្បៈ និងការរិះគន់ផ្នែកអក្សរសាស្ត្រនោះ 'ក្រោយសម័យទំនើបនិយម មិនបានបង្ហាញខ្លួនឡើងនៅក្នុងទស្សនវិជ្ជា និងទ្រឹស្តីសង្គមមុនទសវត្សឆ្នាំ១៩៨០ ជាកន្លែង ដែលវាត្រូវបានផ្សារភ្ជាប់ទៅនឹងស្នាដៃរបស់អ្នកផ្តើមគំនិតបារាំងដូចជា Baudrillard, Deleuze, Derrida, Foucault, and Lyotard។

សម្រាប់អ្នករិះគន់ និងអ្នកការពារលទ្ធិក្រោយសម័យទំនើបនិយម បានផ្សារភ្ជាប់ជាមួយនឹងជំនឿលើវិបត្តិ ក្នុងរូបតំណាងការបោះបង់ចោលទ្រឹស្តីការឆ្លើយឆ្លងនៃសេចក្តីពិត ហេតុផលសកល និងគ្រោងការណ៍ឯកតានៃវឌ្ឍនភាពដែលបានទទួលមរតកពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា។ អ្នករិះគន់ដូចជា Habermas អះអាងថា ការប្រឆាំងសកលនិយមក្រោយសម័យទំនើប គឺមិនអាចផ្តល់ហេតុផល សម្រាប់ការវិនិច្ឆ័យខាងសីលធម៌ ឬនយោបាយ ដែលមិនសូវទូលំទូលាយកម្មវិធីសម្រាប់កំណែទម្រង់សង្គម។ អ្នកការពារតវ៉ាសម្រាប់គោលបំណងមានកម្រិត និងតិចតួចជាងក្នុងការធ្វើការលើដែនកំណត់នៃអ្វីដែលគេអាចគិត ឬនិយាយបាន ដោយហេតុនេះរួមចំណែកដល់ការលេចចេញនូវបទដ្ឋានថ្មី។

## **ទំនាក់ទំនងនឹងស្ថាបនានិយម**

សម័យក្រោយទំនើបនិយម មានការអនុវត្តជាច្រើន សម្រាប់ការស្ថាបនានិយម

[1] Friedrich Nietzsche, *The Will to Power*, trans. Walter Kaufmann (New York: Vintage, 1967); also see David E. Cooper, *World philosophies: An Historical Introduction* (Oxford, U.K, and Cambridge, Mass.: Blackwell, 1996), p.467.

ដែលជាចិត្តវិទ្យា និងវិធីអប់រំ។ ពួកសម័យក្រោយទំនើបនិយម និងពួកស្ថាបនានិយមយល់ឃើញ ថាយើងបង្កើតជំនឿ អំពីចំណេះដឹងពីបទពិសោធយើង។ ព្រោះហេតុដូច្នេះហើយសិស្សបង្កើតទស្សនៈពីចំណេះដឹងតាមអន្តរកម្មជាមួយនឹងបរិស្ថាន។ ចំណេះដឹងដែលជាការបង្កើតឡើងដោយមនុស្ស គឺគ្រាន់តែជាការសាកល្បង និងការប៉ាន់ប្រមាណ និងអាចធ្វើការរំឭកឡើងវិញជាបន្ត នៅពេលដែលសិស្សទទួលបានបទពិសោធថែមទៀត។ ចំណេះដឹងគឺគ្មានទីបញ្ចប់ទេ យើងទទួលបានវាបន្ថែម និងកែលំអ ដោយផ្អែកលើបទពិសោធរបស់យើង។ ការសិក្សាតាមបែបសហការ ដែលជាការបែងចែកបទពិសោធ និងគំនិត តាមរយៈភាសានោះ បង្កើតចំណេះដឹងនូវការស្ថាបនាទាំងបុគ្គល និងសង្គម។

## ១-បញ្ញត្តិជាគន្លឹះ

### ក-Derrida and Foucault

សម័យក្រោយទំនើបនិយម ផ្សារភ្ជាប់ជាមួយនឹងទស្សនវិទូបារាំងMichel Foucault and Jacques Derrida។ Foucault មិនជឿការប្រកាស ចំពោះសច្ចភាពជាសកល និងមិនផ្លាស់ប្តូរ។ គាត់អះអាងថា អ្វីដែលមនុស្សមួយចំនួន ជាពិសេស អ្នកជំនាញការអះអាងថាជាសច្ចភាពសត្យានុម័តនោះ ការវិភាគ បានលាតត្រដាងថាជាសនិទានភាព ដែលស្ថិតក្នុងការប្រើប្រាស់អំណាចទៅលើអ្នកដទៃតាមពេលមួយក្នុងប្រវត្តិសាស្ត្រ[2]។ ពួកសម័យក្រោយទំនើបនិយម ក៏ប្រើប្រាស់ផងដែរនូវបញ្ញត្តិនៃភាពមិនសំខាន់ ឬមិនចាំបាច់។ នៅក្នុងសង្គមណាមួយ ជាពិសេស សង្គមមូលធននិយមទំនើប ដូចជាសហរដ្ឋអាម៉េរិក ពិតជាទទួលបានការគាំទ្រខាងសេដ្ឋកិច្ច សង្គម ការអប់រំវណ្ណៈ និងក្រុមគ្រប់គ្រងអ្នកទាំងឡាយ ដែលជំរុញទៅដល់ការទទួលបានសំឡេងតិចតួចពីសង្គម។

Derrida បានអភិវឌ្ឍទ្រឹស្តីនៃការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការវិភាគន័យ (Deconstruction) ជាវិធីមួយនៃការតាមដានទៅលើដើមកំណើត គឺជាសន្តតិវង្សវិទ្យា (Genealogy) និងអត្ថន័យនៃឯកសារ និងCanons (ជាព្រះគម្ពីរ ឬស្នាដៃមួយ ជាញឹកញាប់ជាសៀវភៅ ដែលឱ្យតម្លៃទៅលើចំ ណេះដឹងអាជ្ញាព្រឹត្តក្នុងវប្បធម៌មួយ)។ ឯកសារគឺ ជាសៀវភៅមួយ ប៉ុន្តែ វាអាចជាការសន្ទនា ភាពយន្ត ឬរឿងល្ខោន ឬប្រភេទផ្សេងទៀត ជាតំណាងវប្បធម៌មួយ។ ក្នុងការអប់រំ ឯកសារ ជាញឹកញាប់ ជាការណែនាំផ្នែកកម្មវិធីសិក្សា វីដេអូ ឬជាសៀវភៅមួយ ដែលរាប់បញ្ចូលទាំង សៀវភៅសិក្សា ដូចជា

[2] John A. Zahorik, *Constructivist Teaching* (Bloomington, Ind.: Phi Delta Kappa Educational Foundation, 1995) pp. 10-13.

សៀវភៅដែលអ្នកកំពុងអាននេះ។ គោលបំណងនៃការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការប្រើប្រាស់ ត្រូវបង្ហាញថា ឯកសារជាជាង់ផ្ទុះបញ្ចាំងសច្ចភាពបែបបរមត្ថវិទ្យាជាការស្តាបនាបែបប្រវត្តិសាស្ត្រ និងវប្បធម៌ ដែលពាក់ព័ន្ធដល់ទំនាក់ទំនងអំណាចខាងនយោបាយ។

ឧទាហរណ៍ អ្នកគាំទ្រកម្មវិធីសិក្សាដ៏ធំមួយ ប្រើប្រាស់សៀវភៅជាគម្ពីរដ៏សំខាន់ ប៉ុន្តែ អ្នកផ្តើមគំនិតសម័យក្រោយទំនើបនិយមជាច្រើន ផ្តល់យោបល់ថា ឯកសារទាំងនេះ សង្កត់ធ្ងន់ទៅលើវប្បធម៌លោកខាងលិច នៅពេលដែលវប្បធម៌អាហ្វ្រិក និងអាស៊ី មានភាពមិនទូលំទូលាយ។ ពួកសម័យក្រោយទំនើបនិយម និយាយថា ឯកសារដូចជាសាធារណរដ្ឋរបស់លោកប្លាតុង និងសីលវិជ្ជារបស់លោកអារីស្តូត មិនមែនជាអំណាចសកល និងស្ថិតស្ថេរ។ ពួកគេគ្រាន់តែជាចំណែកទាំងឡាយជាប្រវត្តិសាស្ត្រ ដែលអាចត្រូវបានគេប្រើប្រាស់។

## ខ-ការពិនិត្យយ៉ាងល្អិតល្អន់នៅលើការបង្កើត និងការប្រើប្រាស់ឯកសារ

ក្នុងការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការប្រើប្រាស់ឯកសារ និងគម្ពីរដ៏សំខាន់ ពួកសម័យក្រោយទំនើបនិយមបានចោទសួរ៖

-តើព្រឹត្តិការណ៍ និងស្ថានភាព នៅពេលពិសេសមួយ ផ្តល់ភាពសំខាន់បែបណាដល់គម្ពីរដ៏សំខាន់?

-តើអ្នកណាផ្តល់ព្រះគម្ពីរនូវឋានៈជាអភ័យឯកសិទ្ធិក្នុងវប្បធម៌ ឬសង្គមមួយ ហើយអ្នកណា ផ្តល់ប្រយោជន៍ពីការទទួលក្នុងនាមជាអ្នកជំនាញមួយ?

-ហេតុអ្វីបានជាព្រះគម្ពីរដ៏សំខាន់រាប់បញ្ចូលទាំងសំឡេងនៃបុគ្គល និងក្រុមដែលមិនសំខាន់ និងមិនមានតំណាង?

ចម្លើយចំពោះសំណួរទាំងនេះ ចង្អុលបង្ហាញដល់អ្នកទាំងឡាយ ដែលកាន់អំណាចអប់រំ នយោបាយ សេដ្ឋកិច្ច និងសង្គម ពិតក្នុងវប្បធម៌ និងសង្គមពិសេសមួយ។

សំណួរអំពីការអប់រំក្នុងប្រព័ន្ធ ផ្តោតអារម្មណ៍ទៅលើរបៀបដែលកម្មវិធីសិក្សាត្រូវបានបង្កើត។ តើឯកសារបែបណា តំណាងឱ្យចំណេះដឹងជាផ្លូវការក្នុងកម្មវិធីសិក្សា? តើយើងបកស្រាយឯកសារយ៉ាងដូចម្តេច ដើម្បីបង្កើត និងរក្សាទំនាក់ទំនងអំណាច នៅក្នុងចំណោមក្រុមផ្សេងៗ?

## ២-សំណួរជាមូលដ្ឋាន

អ្នកអប់រំក្រោយសម័យទំនើបនិយមស្វែងរកដើម្បីបង្កើតញាណ និងនាំមកនូវការផ្លាស់ប្តូរ តាមការពិនិត្យយ៉ាងល្អិតល្អន់ទៅលើការបង្កើត និងការប្រើប្រាស់ការសន្មតតាមប្រពៃណី អំពីចំណេះដឹង ការអប់រំ ការ

សិក្សា និងការបង្រៀន។ គរុវិទូក្រោយសម័យកាលទំនើបនិយម ចាត់ទុកកម្មវិធីសិក្សារបស់សាលារៀន មិនមែនជាកន្លែងរក្សាសច្ចភាពសត្យានុម័តិ និងសេចក្តីថ្លែងបែបវិទ្យាសាស្ត្រ ប៉ុន្តែ ជាកន្លែងនៃទំនាស់ផ្នែកទស្សនៈ គឺមួយចំនួន មានភាពសំខាន់ និងមួយចំនួនផ្សេងទៀត មានភាពបន្ទាប់បន្សំ។

## ក-សាលារៀន បង្កើតស្ថានភាព

គរុវិទូសម័យកាលក្រោយទំនើបនិយម អះអាងថា សាលារៀនសាធារណៈអាម៉េរិក គឺជាភ្នាក់ងារគន្លឹះក្នុងប្រព័ន្ធសេដ្ឋកិច្ច នយោបាយ សង្គម ដែលត្រូវបានធ្វើយុត្តិកម្ម ដោយសនិទានភាពជាផ្លូវការ។ សនិទានភាព ដែលបានបង្កើតដោយអ្នកទាំងឡាយដែលស្វែងរក ដើម្បីធ្វើឱ្យត្រឹមត្រូវតាមច្បាប់នូវឋានៈសង្គម ដែលមានអភ័យឯកសិទ្ធិផ្ទាល់ខ្លួន ហើយនិងដើម្បីដកហូតអំណាចអ្នកផ្សេងទៀត គឺមនុស្សមិនសូវមានសំណាងនោះ រាប់បញ្ចូលទាំងការអះអាងដែលសាលារៀនទាំងឡាយ៖

១-អប់រំដោយយុត្តិធម៌ និងសមភាពដល់កុមារទាំងអស់គ្នា។

២-ជួយសម្រួល បង្កើនដល់**ចល័តភាពសេដ្ឋកិច្ច និងសង្គម**។

៣-ចាំបាច់ ដើម្បីនិរន្តរភាពនៃសង្គមបែបប្រជាធិបតេយ្យ។

ដោយមានទំនាស់ អំពីការអះអាងជាផ្លូវការទាំងនេះ គរុវិទូសម័យក្រោយទំនើបនិយម អះអាងថា សាលាសាធារណៈ ក៏ដូចជាស្ថាប័នសាធារណៈដទៃទៀតដែរ ជួយផលិតជាថ្មីនូវសង្គមមួយដែលជា៖

១-បិតាធិបតេយ្យ (patriarchal) គឺវាផ្តល់ការគាំទ្របុរសជាងស្ត្រី។

២-មជ្ឈមណ្ឌលអឺរ៉ុប (Eurocentric) ចំណេះដឹង ដែលត្រូវបានគេហៅដូច្នោះ មួយភាគធំ គឺជាការស្តាបនាជនស្បែកសនៃខ្សែស្រឡាយពួកអឺរ៉ុប។

៣-ជាពិសេសក្នុងសហរដ្ឋអាម៉េរិក គឺជាពួកមូលធននិយម ដែលទ្រព្យសម្បត្តិឯកជន និងផ្លូវចិត្តរួម បានធ្វើឱ្យចាប់អារម្មណ៍ក្នុងមនោគមវិជ្ជាទីផ្សារសេរី។ បទពិសោធនៃក្រុមផ្សេងទៀត ដូចជាមនុស្ស ដែលមានពណ៌សម្បុរ មិនត្រូវបានរាប់បញ្ចូលអំពីនិទានកថាជាផ្លូវការ របស់កម្មវិធីសិក្សាទេ[3]។

## ខ-ការតស៊ូ ដើម្បីកម្មវិធីសិក្សា

គរុវិទូក្រោយសម័យទំនើបនិយម មើលឃើញកម្មវិធីសិក្សា ជាកន្លែងតស៊ូពិតប្រាកដមួយ គឺសង្គ្រាមវប្បធម៌ ក្នុង

[3] Angeline Martel and Linda Peterat, ''Margins of Exclusion, Margins of Transformation: The Place of Women in Education,'' in Redecca A. Martusewicz and William M. Reynolds, *Inside/Out: Contemporary Critical Perspectives in Education* (New York: St. Martin's Press, 1994), p.152.

ចំណោមក្រុម ដែលប្រជែងគ្នា ដើម្បីអំណាច។ ប្រសិនបើយើង នឹកគិតដល់កម្មវិធីសិក្សាជាផ្នែកមួយនៃការប្រកួតប្រជែងនោះ យើងអាចមើលឃើញពីរបៀប ដែលពិនិត្យយ៉ាងល្អិតល្អន់ ទៅលើការបង្កើត និងការប្រើប្រាស់ដំណើរការ។ ការអះអាងជាច្រើន ត្រូវបានគេធ្វើឱ្យជឿនលឿន សម្រាប់កម្មវិធីសិក្សាគោលខាងវប្បធម៌ តាមស្តង់ដា នៅមធ្យមសិក្សា និងឧត្តមសិក្សា ការផ្តល់យោបល់ សម្រាប់ការទាមទារយ៉ាងសំខាន់មួយ ជាញឹកញាប់ធ្ងុះបញ្ចាំងគម្ពីរតាមប្រពៃណី នៃវប្បធម៌លោកខាងលិច។ គរុវិទូក្រោយសម័យទំនើបនិយម ប្រឆាំងនឹងគម្ពីរយ៉ាងសំខាន់ទាំងនេះ ដែលតំណាងឱ្យតែពួកបុរសមជ្ឈមណ្ឌលទ្វីបអឺរ៉ុបវប្បធម៌មូលធននិយម និងលោកខាងលិច។ ពួកគេអះអាងថា ស្នាដៃទាំងឡាយ ដែលមិនតំណាងឱ្យក្រុមទ្វីបអាហ្វ្រិក អាស៊ី អាម៉េរិកឡាទីន និងជនជាតិដើមភាគតិចកំណើតអាម៉េរិកទេ។ ពួកស្ត្រីនិយមដែលជាក្រុម មិនទទួលបានប្រ យោជន៍ខាងសេដ្ឋកិច្ច ពួកបុរសរួមភេទដូចគ្នា និងពួកនារីរួមភេទដូចគ្នា គួរតែត្រូវបានរាប់បញ្ចូលទៅក្នុងកម្មវិធីសិក្សាគោលនោះផងដែរ។ កម្មវិធីសិក្សាផ្សេងៗ ដែលត្រូវបានគាំទ្រដោយគរុវិទូក្រោយសម័យទំនើបនិ យម គួរតែអនុញ្ញាតឱ្យកុមារទាំងអស់ទទួលបានប្រយោជន៍ពីការសិក្សា។

## គ-ការបង្រៀនជារូបតំណាងមួយ

គរុវិទូក្រោយសម័យទំនើបនិយម ជឿជាក់ថា ការបង្រៀនពាក់ព័ន្ធនឹងរូបតំណាង ដែលមានន័យថា ប្រភេទណាមួយនៃការបញ្ជាក់បង្ហាញខាងវប្បធម៌ ឬការពិភាក្សារាប់បញ្ចូល ទាំងភាសា រឿងនិទាន រូបភាព តន្ត្រី និងការបង្កើតវប្បធម៌ផ្សេងទៀត[4]។ គរុវិទូក្រោយសម័យទំនើបនិយម ជំរុញគ្រូបង្រៀនឱ្យមានតួនាទីប្រកបដោយញាណ និងប្រកបដោយអំណាច និងតម្រូវការ ដើម្បីពិនិត្យយ៉ាងល្អិតល្អន់នូវរូបតំណាង ដែលគាត់បានបង្កើតដល់សិស្ស។ ជាជាងផ្ទេរតែចំណេះដឹង ដែលបានបង្ហាញជាផ្លូវការនោះ គ្រូបង្រៀនត្រូវតែបង្ហាញយ៉ាងល្អិតល្អន់ និងដោយការគិតពិចារណា នូវបទពិសោធរបស់មនុស្សយ៉ាងទូលំទូលាយ[5]។ សិស្សនៅសាលារៀនក្រោយសម័យទំនើបនិយម គួរតែស្តាប់សំឡេង និងរឿងនិទានជាច្រើន ដែលរាប់បញ្ចូលទាំងស្វ័យជីវប្រវត្តិ និងជីវប្រវត្តិ ដែលជាប្រវត្តិមនុស្ស និងសង្គមរបស់សិស្ស ដែលសិក្សា នៅសាលា។ វាមានលក្ខណៈសំខាន់ចាំបាច់ ដែលក្រុមបន្ទាប់ប ន្សំ ត្រូវបានគេ

[4] Elizabeth Ellsworth, ‘’Representation, Self-Representation, and the Meanings of Difference: Questions for Educators,‘’ in Rebecca A. Martusewicz and William M. Reynolds, Inside/Out: Contemporary Critiocal Perspectives in Education (New York: St. Martin’s Press, 1994), p.100

[5] Ibid., pp. 100-101.

ស្តាប់ឮ និងមើលឃើញផ្ទាល់ និងក្លាយជាអ្នកចូលរួមក្នុងការសន្ទនា ដែលបានលើកឡើងប្រកបដោយញាណ[6]។

### ៣-ការអនុវត្ត សម្រាប់គ្រូប្រចាំថ្នាក់នាពេលបច្ចុប្បន្ន

### ក-ការផ្តល់អំណាចដល់គ្រូ

គរុវិទូក្រោយសម័យទំនើបនិយម ជំរុញឱ្យគ្រូផ្តល់អំណាចដល់ខ្លួនឯង តាមរយៈការពិនិត្យមើលឡើងវិញយ៉ាងល្អិតល្អន់ នៃគោលបំណងរបស់សាលារៀន ខ្លឹមសារកម្មវិធីសិក្សា និងការចាត់តាំងតួនាទី និងបេសកកម្មនៃវិជ្ជាជីវៈបង្រៀន។ ការផ្តល់អំណាចឱ្យគ្រូ មានន័យថា គ្រូបង្រៀនទទួលខុសត្រូវ ដើម្បីបង្កើតអនាគតផ្ទាល់ខ្លួនរបស់គេ និងដើម្បីជួយសិស្សឱ្យ បង្កើតជីវិតផ្ទាល់ខ្លួនរបស់គេ[7]។

### ខ-ទីតាំងផ្តោតលើទស្សនវិជ្ជា

លំនាំនៃការផ្តល់អំណាចឱ្យគ្រូ និងសិស្ស ចាប់ផ្តើមនៅក្នុងសាលារៀន និងសហគមន៍ ដែលពួកគេធ្វើការ និងរស់នៅ។ មិនដូចគរុវិទូមនោនិយម និងតថនិយម ដែលទាញយកទស្សនវិជ្ជាអប់រំពីការប៉ាន់ស្មានបែបបរមត្ថវិជ្ជាអរូបីនោះ គរុវិទូក្រោយសម័យទំនើបនិយម ជំរុញឱ្យគ្រូបង្កើតទស្ស នវិជ្ជាអប់រំ ដែលមានទីតាំងផ្ទាល់ខ្លួន។ គ្រូបង្រៀន សិស្ស និងសមាជិកសហគមន៍ ត្រូវតែចាប់ផ្តើមការត្រួតពិនិត្យ ដែលមានទីតាំងច្បាស់លាស់នៃបញ្ហាត្រួតពិនិត្យជាគន្លឹះ តាមការត្រួតពិនិត្យ បញ្ហាដូចជាៈ

១-អ្នកណាត្រួតពិនិត្យសាលារៀន ពិតប្រាកដ បង្កើតកម្មវិធីសិក្សា និងកំណត់ស្តង់ដាសិក្សា?

២-អ្វីជំរុញទឹកចិត្តអ្នកទាំងឡាយ ដែលជាអ្នកគ្រប់គ្រងសាលារៀន?

៣-សនិទានភាពអ្វី ធ្វើយុត្តិកម្មកម្មវិធីសិក្សា ដែលមានស្រាប់?

កម្មវិធីសិក្សា នៅសាលារៀនក្រោយសម័យទំនើបនិយម គួរតែវិភាគបញ្ហានៃអត្តសញ្ញាណបុគ្គលនិងក្រុម ការគ្រប់គ្រង និងទំនាក់ទំនងអំណាច លើកទឹកចិត្តនយោបាយវប្បធម៌ និងការរិះគន់សង្គម ដែលនាំទៅដល់សកម្មភាពរួមៗ ប្រភេទនៃការវិភាគល្អិតល្អន់បែបនេះ នឹងផ្តល់អំណាចដល់មនុស្ស និងប្រែក្លាយសង្គម តាមការប្រឆាំងនឹងប្រយោជន៍ និងអភ័យឯកសិទ្ធិខាងនយោបាយ និងសង្គមដ៏ពិសេស។

### គ-ស្តង់ដា និងការវាយតម្លៃ

### គ-១-គរុវិទូបដ្ឋានវនិយម ពិនិត្យយ៉ាងល្អិតល្អន់ ទៅលើការបង្កើត និងការប្រើប្រាស់ស្តង់ដា

[6] William E. Doll, Jr., A Post-Modern Perspective on Curriculum (New York: Teachers College Press, 1993).

[7] Joe L. Kincheloe, *Toward A Critical Politics of Teacher Thinking: Mapping the postrnodern* (Westport, Conn.: Bergin & Garvey, 1993), p.35.

ការសង្កត់ធ្ងន់របស់គរុវិទូក្រោយសម័យទំនើបនិយម ទៅលើការស្តាប់ឮពីក្រុមផ្សេងៗ បង្ហាញអំណះអំណាងសម្រាប់ភាពផ្សេងៗគ្នាខាងវប្បធម៌ និងពហុវប្បធម៌និយមក្នុងសាលារៀនទាំងឡាយ។ ជាងនេះទៀត គរុវិទូក្រោយសម័យទំនើបនិយម ចោទសួរយ៉ាងល្អិតល្អន់ អំពីស្តង់ដាទាំងឡាយ ជាពិ សេស នៅពេលដែលសាលារៀនប្រើប្រាស់តេស្តតាមស្តង់ដា ដើម្បីវាស់វែងស្នាដៃសិស្ស។ ជាពិសេស ពួកគេគួរតែស្រាវជ្រាវសម្រាប់ទំនាក់ទំនងអំណាច ដោយការសាកសួរថា តើនរណាជាអ្នកប្រគល់អាណត្តិធ្វើតេស្ត នរណាអភិវឌ្ឍតេស្ត នរណាបកស្រាយលទ្ធផលតេស្ត លទ្ធផលនឹងត្រូវបានប្រើប្រាស់យ៉ាងដូចម្តេច ហើយតើតួនាទីបែបណា ដែលអ្នកនយោបាយ មាតាបិតា គ្រូបង្រៀន និងសិស្សត្រូវអនុវត្ត ក្នុងការកំណត់ស្តង់ដា និងប្រើប្រាស់តេស្ត ដើម្បីផ្ទៀងផ្ទាត់ប្រសិនបើស្តង់ដាត្រូវបានគេធ្វើយតប។

សំណួរស្រដៀងគ្នា គួរអនុវត្ត ដើម្បីវិភាគការប្រើប្រាស់បច្ចេកវិជ្ជាក្នុងថ្នាក់រៀន។ អ៊ិនធឺណិត អាចផ្តល់អំណាច ដល់មនុស្សតាមការបង្កើតមធ្យោបាយទំនាក់ទំនង ដើម្បីបែងចែកគំនិត និងការព្រួយបារម្ភរួមជាមួយគ្នាទៅវិញទៅមក។ ដូចគ្នានេះដែរ បច្ចេកវិជ្ជាប្រសិនបើត្រូវបានគ្រប់គ្រងដោយក្រុមដ៏សំខាន់នោះអាចជួយអប់រំមនុស្ស ដើម្បីទទួលយកស្ថានភាពដដែលៗ ដើម្បីដកហូតអំណាចពួកគេ។ គ្រូបង្រៀនក្រោយសម័យទំនើបនិយម គួរតែមានភាពជឿជាក់ ដើម្បីពិនិត្យរូបតំណាងក្នុងកម្មវិធី សម្រាប់ការប្រើប្រាស់របស់សិស្ស ព្រមទាំងដើម្បីពិចារណាបញ្ហានៃអំណាច ដែលមានការពាក់ព័ន្ធ ដល់ការរៀបចំសិស្សឱ្យទទួលបានបច្ចេកវិជ្ជា។

## គ-២-មេរៀនការអប់រំតាមបច្ចានទនិយម

តើមេរៀនគរុវិទូក្រោយសម័យទំនើបនិយម មានលក្ខណៈដូចម្តេច? សិស្សនៅក្នុងថ្នាក់រៀនប្រវត្តិវិទ្យា នៅសាលាមធ្យមសិក្សាអាម៉េរិក អាចពិនិត្យមើលពីរបៀបជនជាតិម៉ិកស៊ិក រស់នៅក្នុងដែនដី ដែលប្រទេសម៉ិកស៊ិក ត្រូវបានគេបង្ខំ ប្រគល់ឱ្យសហរដ្ឋអាម៉េរិក ក្រោយសង្គ្រាមម៉ិកស៊ិកលែងមានភាពសំខាន់។ បន្ទាប់មក គេអាចពិភាក្សាពីរបៀបដែលជនជាតិឡាតាំងនិងក្រុមបន្ទាប់បន្សំផ្សេងទៀតបានបង្កើតសំឡេង ដែលត្រូវបានគេឮពាសពេញប្រវត្តិសាស្ត្រអាម៉េរិក។ មេរៀន អាចរាប់បញ្ចូលពីកិច្ចការទិនានុប្បវត្តិ ដែលក្នុងនោះ សិស្ស ពិនិត្យមើលផ្នែកទាំងឡាយនៃជីវិតរបស់គេនៅកន្លែង ដែលគេមានអារម្មណ៍ថា ទទួលបានអំណាច ឬមិនមានភាពសំខាន់ហើយផ្តល់យោបល់ និងសកម្មភាពមួយចំនួន ដែលគេជឿជាក់ថា នឹងអាចជួយឱ្យសំឡេងពួកគេត្រូវបានឮ តាមរបៀបស្ថាបនា។

## សន្និដ្ឋាន

ទ្រឹស្តីបច្ឆានវនិយម ដែលទទួលបានពីការទ្រដោយលោក Derrida និង Foucault ជាទ្រឹស្តីទស្សនវិជ្ជាសំខាន់មួយ ដែលត្រូវបានគេយក ទៅប្រតិបត្តិក្នុងវិស័យអប់រំ ដែលថា សាលារៀន គឺជាកន្លែងនៃការរិះគន់បែបប្រជាធិបតេយ្យ និងការផ្លាស់ប្តូរសង្គម ដើម្បីផ្តល់អំណាចដល់ក្រុមដែលត្រូវគេត្រួតត្រាឬគ្រប់គ្រង

## ឯកសារយោង


1- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.

2- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.

3- Friedrich Nietzsche, *The Will to Power*, trans. Walter Kaufmann, New York: Vintage, 1967.

4- David E. Cooper, *World philosophies: An Historical Introduction*, Oxford, U.K, and Cambridge, Mass.: Blackwell, 1996.

5- John A. Zahorik, *Constructivist Teaching*, Bloomington, Ind.: Phi Delta Kappa Educational Foundation, 1995.

6- Angeline Martel and Linda Peterat, *''Margins of Exclusion, Margins of Transformation: The Place of Women in Education,''* in Redecca A. Martusewicz and William M. Reynolds, *Inside/ Out: Contemporary Critical Perspectives in Education*, New York: St. Martin's Press, 1994.

7- Elizabeth Ellsworth, ''*Representation, Self-Representation, and the Meanings of Difference: Questions for Educators,*'' in Rebecca A. Martusewicz and William M. Reynolds, Inside/Out: Contemporary Critiocal Perspectives in Education, New York: St. Martin's Press, 1994.

8- William E. Doll, Jr., A Post-Modern Perspective on Curriculum, New York: Teachers College Press, 1993.

9- Joe L. Kincheloe, *Toward A Critical Politics of Teacher Thinking: Mapping the postrnodern* Westport, Conn.: Bergin & Garvey, 1993.